# ឥឡូវយើងជួបគ្នាម្ដងទៀត

*ដោយប្រធាន ថូម៉ាស អេស ម៉នសុន*

បងប្អូនប្រុសស្រី ជាការល្អអ្វីម្ល៉េះ ដោយបានស្វាគមន៍អ្នកទាំងអស់គ្នា មកកាន់សន្និសីទទូទៅពាក់កណ្ដាលឆ្នាំលើកទី 181 របស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

សន្និសីទនេះគម្រប់ខួបលើកទី 48 ឆ្នាំ ចាប់តាំងពីខ្ញុំត្រូវបានហៅចូលមកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដោយប្រធាន ដេវីឌ អូ មិកឃេ ។ គឺក្នុងខែតុលា ឆ្នាំ 1963 ។ វាមិនគួរឲ្យជឿទេថា ជាច្រើនឆ្នាំបានកន្លងហួសទៅហើយ ។

ពេលយើងមានភាពមមាញឹក នោះពេលវេលាហាក់ដូចជាដើរលឿនណាស់ ហើយរយៈពេលប្រាំមួយខែកន្លងទៅនេះក៏មិនលើកលែងដែរសម្រាប់ខ្ញុំ ។ ការណ៍ដ៏សំខាន់មួយ អំឡុងពេលនោះគឺ នៅថ្ងៃទី 1 ខែ ឧសភា ខ្ញុំមានឱកាសឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ អាត្លង់តា ចចា ឡើងវិញ ដោយមាន អែលឌើរ និងស៊ិស្ទើរ អិម រ័សុល បាឡឺដ, អែលឌើរ និងស៊ិស្ទើរ វ៉លធើរ អែហ្វ ហ្គុងស្សាឡែស្ស ព្រមទាំងអែលឌើរ និងស៊ិស្ទើរ
វីល្លាម អរ វ៉កឃើរ អមដំណើរជាមួយខ្ញុំ ។

ក្នុងអំឡុងការប្រារព្ធពិធីវប្បធម៌ ដែលមានចំណងជើងថា « ពន្លឺទិសខាងត្បូង » ដែលបានប្រារព្ធឡើងនៅល្ងាចមុនថ្ងៃឧទ្ទិសនោះ យើងបានមើលការសម្ដែងរបស់យុវវ័យចំនួន 2,700 នាក់ មកពីទូទាំងមណ្ឌលព្រះវិហារបរិសុទ្ធ ។ វាជាកម្មវិធីដ៏ល្អបំផុតមួយដែលខ្ញុំធ្លាប់ឃើញ ហើយដែលធ្វើឲ្យទស្សនិកជនក្រោកឈរអបអរសាទរជាច្រើនដង ។ ថ្ងៃបន្ទាប់ ព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងសារឡើងវិញជាលើកទីពីរ ហើយព្រះវិញ្ញាណនៃព្រះអម្ចាស់បានគង់ជាមួយយើងយ៉ាងបរិបូណ៌ ។

អំឡុងចុងខែសីហា ប្រធាន ហិនរី ប៊ី អាវរិង បានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ សានសាល់វ៉ាដ័រ អេលសាល់វ៉ាដ័រ ។ លោកត្រូវបានអមដំណើរដោយស៊ិស្ទើរ អាវរិង, អែលឌើរ និងស៊ិស្ទើរ ឌី ថត គ្រីស្តូហ្វឺសិន, អែលឌើរ និងស៊ិស្ទើរ វីល្លាម អរ វ៉កឃើរ និងស៊ិស្ទើរ ស៊ីលវ៉ា អាល់វ៉ែត នៃគណៈប្រធានសមាគមសង្គ្រោះទូទៅ ព្រមទាំងស្វាមីរបស់គាត់ ជេហ្វ្រី ។ ប្រធាន អាវរិង បានរាយការណ៍ថា វាជាព្រឹត្តិការណ៍មួយដែលពោរពេញដោយព្រះវិញ្ញាណខ្លាំងណាស់ ។

ក្នុងចុងឆ្នាំនេះ ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ និងស៊ិស្ទើរ អុជដូហ្វ អមដំណើរដោយពួកអ្នកមានសិទ្ធិអំណាចទូទៅនឹងធ្វើដំណើរទៅកាន់ទីក្រុង ហ្កេតហ្សាល់ណង់ហ្គូ ប្រទេសហ្គាតេម៉ាឡា ដើម្បីលោកនឹងធ្វើការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធរបស់យើងនៅទីនោះ ។ បងប្អូនប្រុសស្រី ការសាងសង់ព្រះវិហារបរិសុទ្ធបន្តឥតឈប់ឈរ ។ ថ្ងៃនេះ ជាឯកសិទ្ធិរបស់ខ្ញុំ ក្នុងការប្រកាសព្រះវិហារបរិសុទ្ធថ្មីៗមួយចំនួនទៀត ។

ដំបូង ខ្ញុំសូមលើកឡើងថា គ្មានអគារសាសនាចក្រដែលបានសាងសង់ឡើងណាមួយ សំខាន់ជាងព្រះវិហារបរិសុទ្ធឡើយ ។ ព្រះវិហារបរិសុទ្ធ ជាទីកន្លែងដែលទំនាក់ទំនងទាំងឡាយត្រូវបានផ្សារភ្ជាប់ ឲ្យនៅអស់កល្បជានិច្ច ។ យើងមានអំណរគុណសម្រាប់ព្រះវិហារបរិសុទ្ធជាច្រើននៅទូទាំងពិភពលោក និងសម្រាប់ពរជ័យនៃព្រះវិហារបរិសុទ្ធដែលបានកើតមានក្នុងជីវិតរបស់សមាជិកយើង ។

នៅចុងឆ្នាំមុន រោងឧបោសថនៅទីក្រុងប្រូវ៉ូ ក្នុងយូថាហ៍ បានទទួលរងការខូចខាតយ៉ាងខ្លាំង ដោយភ្លើងដ៏សន្ធោសន្ធៅមួយ ។ អគារដ៏ស្រស់ស្អាតនេះដែលត្រូវបានពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនជំនាន់មានការស្រឡាញ់ពេញចិត្ត នៅសល់តែជញ្ជាំងខាងក្រៅឈរតាំងនៅទ្រឹង ។

បន្ទាប់ពីការសិក្សាដោយយកចិត្តទុកដាក់មក យើងបានសម្រេចចិត្តដើម្បីសាងសង់វាឡើងវិញ ដោយរក្សា និងស្ដារផ្នែកខាងក្រៅឡើងវិញ ដើម្បីឲ្យក្លាយទៅជាព្រះវិហារបរិសុទ្ធទីពីរនៃសាសនាចក្រនេះនៅក្នុងទីក្រុងប្រូវ៉ូ ។ ព្រះវិហារបរិសុទ្ធប្រូវ៉ូដែលមានពីមុនគឺជាព្រះវិហារបរិសុទ្ធមួយនៃសាសនាចក្រនេះដែលមានការមមាញឹកបំផុត ហើយព្រះវិហារបរិសុទ្ធទីពីរនេះនឹងជួយសម្រួលដល់ការកើនឡើងនូវចំនួននៃសមាជិកសាសនាចក្រដ៏ស្មោះត្រង់ដែលកំពុងតែចូលរួមក្នុងព្រះវិហារបរិសុទ្ធមកពីទីក្រុងប្រូវ៉ូ និងតំបន់ជុំវិញនោះ ។

ខ្ញុំក៏មានក្ដីរីករាយដើម្បីប្រកាសនូវព្រះវិហារបរិសុទ្ធថ្មីនៅក្នុងតំបន់ដូចតទៅនេះ ៖ បារ៉ាន់ហ្គីលឡា, កូឡុំប៊ី, ឌឺបាន, អាហ្វ្រិកខាងត្បូង ។ គីនហ្សាសា នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។ និងស្ដារវិល្លី វ៉ាយអូមីង ។ ជាមួយគ្នានេះដែរ យើងកំពុងរំកិលឆ្ពោះទៅមុខក្នុងផែនការរបស់យើងដើម្បីសាងសង់ព្រះវិហារបរិសុទ្ធមួយក្នុងទីក្រុងប៉ារីសប្រទេសបារាំង ។

ព័ត៌មានលម្អិតអំពីព្រះវិហារបរិសុទ្ធទាំងនេះ នឹងត្រូវបានផ្តល់ក្នុងពេលខាងមុខ ពេលយើងបានទទួលព័ត៌មានពីកន្លែង និងការអនុញ្ញាតចាំបាច់ផ្សេងទៀត ។

ខ្ញុំបានលើកឡើងក្នុងសន្និសីទកាលពីលើកមុន ពីការរីកចម្រើន ដែលយើងមានក្នុងការដាក់ព្រះវិហារបរិសុទ្ធឲ្យនៅជិតសមាជិក ។ ថ្វីបើព្រះ-វិហារបរិសុទ្ធមាននៅជិតសមាជិកសាសនាចក្រជាច្រើនក្តី តែនៅតែមានតំបន់នានានៅលើពិភពលោកដែលព្រះវិហារបរិសុទ្ធនៅឆ្ងាយពីសមាជិកយើង ដែលធ្វើឲ្យពួកគេពុំអាចមានលទ្ធភាពធ្វើដំណើរទៅបានទេ ។ ហេតុនោះ ពួកគេពុំអាចទទួលពរជ័យដ៏ពិសិដ្ឋ និងអស់កល្បដែលព្រះ-វិហារបរិសុទ្ធផ្តល់ឲ្យបានទេ ។ ដើម្បីជួយក្នុងកិច្ចការនេះ យើងមានអ្វីមួយ ដែលហៅថា មូលនិធិជំនួយផ្ទះព្រះវិហារបរិសុទ្ធ។ មូលនិធិនេះ ផ្តល់ថវិកាសម្រាប់ការទៅព្រះវិហារបរិសុទ្ធម្តង សម្រាប់អ្នកដែលពុំមានលទ្ធភាពទៅព្រះវិហារបរិសុទ្ធ តែមានបំណងយ៉ាងខ្លាំងសម្រាប់ឱកាសនោះ ។ អស់អ្នកណាដែលចង់បរិច្ចាគដល់មូលនិធិនេះ អាចសរសេរព័ត៌មានលើក្រដាសដង្វាយ ដែលជូនទៅប៊ីស្សពជារៀងរាល់ខែ ។

ឥឡូវនេះ បងប្អូនប្រុសស្រី នេះជាការអធិស្ឋានរបស់ខ្ញុំ ថាយើងអាចត្រូវបានបំពេញដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ កាលដែលយើងស្តាប់សារដំណឹងនៅថ្ងៃនេះ និងថ្ងៃស្អែក ហើយរៀនការណ៍ទាំងនោះ ដែលព្រះ-អម្ចាស់មានព្រះទ័យចង់ឲ្យយើងដឹង ។ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។